រាជបណ្ឌិត្យសភាកម្ពុជា

វិទ្យាស្ថានភាសាជាតិ



អត្ថបទស្រាវជ្រាវ

ស្តីពី

# សិលាចារឹកវត្តពោធិមុនី ហៅវត្តស្វាយចេកថ្មី


ដោយ៖

បណ្ឌិត មាយ ម៉ូរ៉ា

កញ្ញា ពេជ្រ ណាទីន


ខែមីនា ឆ្នាំ២០១៩

# សិលាចារឹកវត្តពោធិមុនី ហៅវត្តស្វាយចេកថ្មី

ដោយៈ បណ្ឌិត **មាឃ បូរ៉ា** និង កញ្ញា **ពេជ្រ ណាទីន**

តាមរយៈលោក **លាង សុភាព** មន្ត្រីក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិត្យសភាកម្ពុជា លោកបានផ្តល់ព័ត៌មានថា មានសិលាចារឹកមួយផ្ទាំងនៅវត្តពោធិមុនី ហៅវត្តស្វាយចេកថ្មី ស្ថិតនៅក្នុងភូមិស្វាយចេក ឃុំស្វាយចេក ស្រុករំដួល ខេត្តស្វាយរៀង ដែលមានចម្ងាយប្រហែល ១៣គីឡូម៉ែត្រពីទីរួមខេត្ត។ អាស្រ័យហេតុនេះហើយ ទើបក្រុមស្រាវជ្រាវដែលមានគ្នាបីនាក់នៅក្នុងនោះ មានខ្ញុំ(បណ្ឌិត **មាឃ បូរ៉ា**)មន្ត្រីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា, បណ្ឌិត **សន ពៅ** អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ និង កញ្ញា **ពេជ្រ ណាទីន** បានទៅដល់ទីអារាមនោះនៅថ្ងៃសៅរ៍ ទី២៩ ខែធ្នូ ឆ្នាំ២០១៨ ហើយ បានក្រាបបង្គំទូលសួរព្រះភិក្ខុ **គង់ សំណាង** ខេមចារោ ដែលជាចៅអធិការវត្តនៃវត្តពោធិមុនីទាក់ទងនឹងសិលាចារឹកនោះ។ ព្រះភិក្ខុមានសង្ឃដីកាថា ពិតជាមានសិលាចារឹកនោះមែន ប៉ុន្តែ នាពេលនោះ ក្រុមយើងខ្ញុំមិនបានមើលសិលាចារឹកនោះទេ ពីព្រោះមានពុទ្ធបរិស័ទដែលជាសាច់ញាតិអតីតៈព្រះគ្រូចៅអធិការដែលបានសុគតទៅ ក៏បានយកសិលាចារឹកនោះទៅដាក់ក្នុងចេតិយចាក់សោរទៅហើយ។ លុះដល់ថ្ងៃសៅរ៍ ទី០២ ខែមីនា ឆ្នាំ២០១៩ ខ្ញុំនិងក្រុមនិស្សិតវិទ្យាស្ថានសង្គមសាស្ត្រនិងបច្ចេកវិទ្យាបានទៅមើលម្តងទៀត ហើយក៏បានមើលនិងថតសិលាចារឹកនោះ។

សិលាចារឹកនេះចារនៅលើគោលសីមាថ្មភក់ពណ៌ក្រហម ដែលមានកម្ពស់០,៥៨ម៉ែត្រ, បណ្តោយ(បន្ទារមុខ)មានប្រវែង ០,២៩ម៉ែត្រ និង ទទឹង(បន្ទារទទឹង)មានកម្រាស់ ០,៨៥សង់ទីម៉ែត្រ។ សិលាចារឹកនេះសរសេរជាភាសាខ្មែរទម្រង់បែបអក្សរជ្រៀង មាន១៦បន្ទាត់ ដែលមានចុះកាលបរិច្ឆេទឆ្នាំ៨៥៧នៃមហាសករាជ ត្រូវនឹងឆ្នាំ៩៣៥នៃគ្រិស្តសករាជ។ បើគិតតាមឆ្នាំ៩៥៣គ.ស.នេះ គឺចារឡើងក្នុងរាជ្យរបស់ព្រះបាទ **ជ័យវរ្ម័នទី៤** (៩២៨-៩៤១គ.ស.) ដែលព្រះនាមរបស់ព្រះអង្គនៅពេលសោយរាជ្យសម្បត្តិ គឺធូលីព្រះបាទធូលីជេងព្រះកម្រតេងអញ***ជយវម្ម៌ទេវៈ***។ រីឯបច្ឆាមរណនាមរបស់ព្រះអង្គ គឺព្រះបាទ***បរមសិវបទ***។



## ១- សំណោរអក្សរខ្មែរបុរាណ[1]

១- សិទ្ធិស្វស្តិ ៨៥៧ គក្ក

២- បិកេតិវៃគាខនុមានិវ្រះ

៣- គានធ្វលីជេង៑វ្រះកម្រតេ[ង៑]

៤- អញ្ជិតកំស្តេង៑អញ្ជិគ្រីជយ

៥- វិរវម្មិតម្រតាញ្ជិខ្លោញ្ជិគ្រីក

៦- វិគ្វរវម្មវ៌្វជាបិប្រេនេះអ្នក

៧- ទំនង៑វ្រះឆ្នា[ំ]វ្រះវិនាយ

៨- តកាល្បតជោតិទ្វេបុជាវ្រ[ះ]

៩- កម្រតេង៑អញ្ជិគីបលិក្តអាយ

១០- ទំនង៑កុសិខ[យិ]មិនាំនាវ្រះកំ

១១- ម្រតេង៑អញ្ជាខកតិ.........[លេង៑]

១២- ផោះបាកល្បនាយខមានធ្វេ

១៣- វ្រះវាខកាល្យនាម្វលគល្ប

១៤- ទ្វជាបិនាវិបល្យង៑ទ្វជាបិនា

១៥- វិទ្រិបាទ្វជាបិនាវិ[ត]ម្វលឆោ

១៦- ង៑។

## ២- សំណោរអក្សរខ្មែរទំនើប

១- សិទ្ធិស្វស្តិ ៨៥៧ គក្ក

២- បិកេតិវៃគាខនុមានិវ្រះ

៣- គានធ្វលីជេង៑វ្រះកម្រតេ[ង៑]

៤- អញ្ជិតកំស្តេង៑អញ្ជិគ្រីជយ

៥- វិរវម្មិតម្រតាញ្ជិខ្លោញ្ជិគ្រីក

៦- វិគ្វរវម្មវ៌្វជាបិប្រេនេះអ្នក

៧- ទំនង៑វ្រះឆ្នា[ំ]វ្រះវិនាយ

[1] ពុម្ពអក្សរបុរាណនេះកំពុងរចនាមិនទាន់រួចរាល់។

៨- តកាយ៌្យតទៃតិថ្វេបុជាវ្រ[ះ]

៩- កម្រតេង៑អញ៑ឝិវលិង្គអាយ

១០- ទំនង៑គុសឱ[យ៑]ចំនាំនាវ្រះកំ

១១- ម្រតេង៑អញជគត.........[លេង៑]

១២- រោះហកល្បនាយជមានថ្វេ

១៣- វ្រះរាជកាយ៌្យនាមូលឥស្ស

១៤- វ្វំជាបីទារ៑បយ្យង៑វ្វំជាបិទា

១៥- រ៑វ្រិហិវ្វំជាបិទារ៑[ត]មូលផោ

១៦- ង៑។

## ៣- សំណេរប្រតិចារឹកអក្សរ

1. siddhi svasti 857 çakka
2. pi ket vaiçāhka nu mān vraḥ
3. çāna dhulī jeṅ vraḥ kamrate[ṅ]
4. añ ta kaṃsteṅ añ çrī jaya
5. viravarmma ta mratāñ khloñ çrī ka
6. viçvaravarmma vvaṃ jā pi pre neḥ ªnak
7. daṃnaṅ vraḥ chā[ṃ] vraḥ vināya
8. ta kāryya ta dai ti thve pujā vra[ḥ]
9. kamrateṅ añ çivaliṅga āy
10. daṃnaṅ gus o[y] caṃnāṃ nā vraḥ kaṃ
11. mrateṅ añ jagat ……[leṅ]
12. roḥha kalpanā yajamāna thve
13. vraḥ rājakāryya nā mūla iss
14. vvaṃ jā pī dār paryyaṅ vvaṃ jā pi dā
15. r vrihi vvaṃ jā pi dār [ta] mūla pho
16. ṅ

## ៤- សេចក្ដីប្រែ

(១-)សូមមានសិទ្ធិសិរីសួស្ដី ឆ្នាំ៨៥៧នៃមហាសករាជ(ត្រូវនឹងឆ្នាំ៩៣៥គ.ស.) (២-)បីកើត ខែពិសាខ មានព្រះរាជ(៣-)បញ្ជានៃធូលីជេងព្រះកម្រតេងអញ(ដែលជាគោរមងាររបស់ព្រះមហាក្សត្រព្រះបាទ**ជ័យវរ្ម័នទី៤**)(៤-) (ត្រាស់បង្គាប់)ដល់មន្ត្រីកំស្ដេងអញស្រី*ជយ* (៥-) *វិរវម៌្ម* (ជ័យវិរវរ្ម័ន) ដល់មន្ត្រីម្រតាញខ្លោញស្រី*ក* (៦-) វិគ្វរវម៌្ម(កវិស្វរវរ្ម័ន) ពុំគប្បីប្រើអ្នកទាំងនេះ(៧-)

(នៅឯតំបន់)ទំនង[2] ដែលជាឆ្នាំទេវស្ថាន ព្រះវិន័យក្បួនច្បាប់(៨-) ចំពោះកិច្ចការងារដទៃទៀត ត្រូវបានរៀបចំធ្វើសក្ការបូជាដល់ព្រះ(៩-) កម្រតេងអញសិវលិង្គនៅឯ(តំបន់)(១០-) ទំនង ប៉ុណ្ណោះ ឱ្យរៀបចំគ្រឿងសក្ការបូជានៅក្នុង(១១-) ប្រាសាទ......[ឡើង](១២-) ការរៀបចំគ្រឿង សក្ការៈទាំងនេះដែលអ្នកមានកុសលផលបុណ្យធ្វើ(១៣-) ព្រះរាជការបានឱ្យថៃរក្សាគ្រប់គ្រង ទាំងអស់(១៤-) ពុំគប្បីទារប្រេង ពុំគប្បីទារ(១៥-) គ្រាប់ធញ្ញជាតិ ពុំគប្បីទារនូវការគ្រប់គ្រង (១៦-) ផងទាំងឡាយ។



[2] សម្មតិកម្មពាក្យនេះ អាចមានន័យថា ដើមធ្នង់។







